បេឡាជាតិសន្តិសុខសង្គម
National Social Security Fund

ព្រឹត្តិបត្រព័ត៌មានបេឡាជាតិសន្តិសុខសង្គម

# ប.ស.ស. ឆ្នាំទី ១០
## លេខ ២៧ ឆ្នាំ ២០១៩





ធានាសន្តិសុខប្រាក់ចំណូល
រួមចំណែកកាត់បន្ថយភាពក្រីក្រ
លើកកម្ពស់ស្ថិរភាពសង្គម

ទំនាក់ទំនងឯបន្ទាន់
**១២៨៦**
**២៤ម៉ោង/៧ថ្ងៃ**

# ព្រឹត្តិបត្រព័ត៌មាន
# ប.ស.ស.
## មាតិកា




០១ រាជរដ្ឋាភិបាលកម្ពុជា សម្រេចបោះពុម្ពក្រដាសប្រាក់គំរូថ្មី ១៥.....០១

០២ រាជរដ្ឋាភិបាលកម្ពុជា អនុម័តលើសេចក្ដីព្រាងច្បាប់ស្ដីពី «របប...០២

០៣ ការចូលរួមអនុវត្តផែនការសកម្មភាព សុវត្ថិភាពចរាចរណ៍ផ្លូវ.....០៤

០៤ ប្រតិភូ នៃបេឡាជាតិរបបសន្តិសុខសង្គមកម្ពុជា ចូលរួមលើក.....០៦

០៥ ថ្នាក់ដឹកនាំ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) នៃ...... ០៩

០៦ កិច្ចប្រជុំពិគ្រោះយោបល់ជាមួយមូលដ្ឋានសុខាភិបាលឯកជន.....១០

០៧ មន្ត្រីបេឡាជាតិរបបសន្តិសុខសង្គម ប.ស.ស. នៃក្រសួងការងារ..១២

០៨ ឯកឧត្តម ស៊ុំ សោភ័ណ នាយករង ប.ស.ស. និងមន្ត្រីជំនាញ....១៤

០៩ មន្ត្រី ប.ស.ស. រៀបចំកិច្ចប្រជុំពិភាក្សាលើកម្មវិធីពិគ្រោះ និង....១៥

១០ មន្ត្រីជំនាញបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) នៃ......១៧

១១ កិច្ចប្រជុំក្រុមការងារបច្ចេកទេសនៃគម្រោង SPIN ស្ដីពី........១៨

១២ អ្នកបើកបរយានយន្តដឹកកម្មករនិយោជិតចំនួន ២៩២នាក់ ......២០

១៣ កិច្ចប្រជុំផ្សព្វផ្សាយច្បាប់ស្ដីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក.........២២

១៤ មន្ត្រីជំនាញ នៃបេឡាជាតិរបបសន្តិសុខសង្គមកម្ពុជាចូលរួម......២៤

១៥ មន្ត្រីជំនាញបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ.....២៥

១៦ មន្ត្រីជំនាញ ប.ស.ស. កម្ពុជា និងសមាជិកអាស៊ានចំនួន ........២៧

១៧ ការផ្សព្វផ្សាយអប់រំអំពីច្បាប់ចរាចរណ៍ផ្លូវគោកជូនដល់អ្នក.......២៩

១៨ មើលមនុស្សដោយស្មារតី....................................... ៣២

១៩ អាហារ៦មុខសម្រាប់អ្នកភ្នែកម៉្យូបមិនគួរមើលរំលង............... ៣៣






## រចនាសម្ព័ន្ធព្រឹត្តិបត្រ

### ឯកឧត្តម អ៊ុក សមវិទ្យា
### នាយក ប.ស.ស.

| | |
|---|---|
| ចាងហ្វាង | ឯកឧត្តម ហេង សុផាន់ណារិទ្ធ |
| និពន្ធនាយក | លោក យ៉ាម យុទ្ធា |
| និពន្ធនាយករង | លោក ឃុន វិចិត្រ |
| | លោក វ៉ាន់ ចាន់ថន |
| លេខានិពន្ធ | កញ្ញា រ៉ាត់ ម៉ាលីកា |
| | លោក នាង ឌូ |
| | លោក យន គន្ធា |
| | លោក អ៊ឹង លាងឆុង |
| | លោក លឹម តក់ |
| ផ្នែកការីកុំព្យូទ័រ | លោក ប៊ុត ស៊ីម |
| | លោក យង់ សុខន |
| | លោក អ៊ុង ស៊ីខឿ |



# រាជរដ្ឋាភិបាលកម្ពុជា សម្រេចបោះពុម្ពក្រដាសប្រាក់គំរូថ្មី ១៥០០០រៀល ដើម្បីអបអរសាទរគម្រប់ខួប១៥ព្រះវស្សា នៃការឡើងគ្រងរាជ្យសម្បត្តិរបស់ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខដឹកនាំ បានសម្រេចបោះពុម្ពក្រដាប្រាក់គំរូថ្មី ១៥០០០ រៀល ដើម្បីអបអរសាទរ ក្នុងឱកាសព្រះរាជពិធីបុណ្យគម្រប់ខួប ១៥ ព្រះវស្សា នៃការយាងគ្រងព្រះបរមសិរីរាជ្យសម្បត្តិ ព្រះករុណាជាអម្ចាស់ជីវិតកម្ពល់លើត្បូង ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។

ក្រដាសប្រាក់គំរូថ្មី១៥០០០រៀល នឹងគ្រោងដាក់ឱ្យចរាចរណ៍នៅពេល ខាងមុខនេះ ធ្វើឡើងនៅព្រឹកថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៩ ក្នុងឱកាសព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង **ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រីនរោត្តម មុនិនាថ សីហនុ** ព្រះវររាជ មាតាជាតិខ្មែរ សព្វព្រះរាជហឫទ័យប្រោសព្រះរាជានុញ្ញាតឱ្យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង **ឯកឧត្តម ជា ចាន់តូ** អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ចូលក្រាបថ្វាយបង្គំគាល់ នៅព្រះមហាប្រាសាទខេមរិន្ទ ក្នុងព្រះបរមរាជវាំង។ នេះបើតាមការចុះផ្សាយរបស់ទូរទស្សន៍ជាតិនៃកម្ពុជា។

សូមជម្រាបថា នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ ២០១៩ គឺជាព្រះរាជពិធីបុណ្យខួបលើកទី ១៥ នៃការយាងគ្រងព្រះបរមសិរីរាជសម្បត្តិ របស់ព្រះមហាក្សត្រ **ព្រះករុណា ព្រះបាទ សម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**៕









# រាជរដ្ឋាភិបាលកម្ពុជា អនុម័តលើសេចក្តីព្រាងច្បាប់ស្តីពី «របបសន្តិសុខសង្គម»

រាជរដ្ឋាភិបាលកម្ពុជា អនុម័តលើសេចក្តីព្រាងច្បាប់ស្តីពី «របបសន្តិសុខសង្គម» សេចក្តីព្រាងច្បាប់ស្តីពី«របបសន្តិសុខសង្គម» ត្រូវបានគណៈរដ្ឋមន្ត្រីអនុម័តទាំងស្រុងហើយ នៅក្នុងកិច្ចប្រជុំដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានាព្រឹកថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩។

**ឯកឧត្តម ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល បានឱ្យដឹងថា ច្បាប់ស្តីពីរបបសន្តិសុខសង្គមនេះមានវិសាលភាពទូលំទូលាយ ដែលនឹងជំនួសឱ្យច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលបានប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រម នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលជាក្របខ័ណ្ឌគតិយុត្តគោលដំបូង ក្នុងការដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា។



សេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គមនេះ មានគោលបំណងបង្កើតឱ្យមានរបបសន្តិសុខសង្គមកម្ពុជា តាមគោលការណ៍សាមគ្គីធម៌ និងសមធម៌សង្គម ដែលរួមមាន ៤ផ្នែក គឺផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកនិកម្មភាពការងារ សម្រាប់បុគ្គលដែលស្ថិតក្នុងវិស័យសាធារណៈ បុគ្គលដែលស្ថិតក្រោមច្បាប់ស្តីពីការងារ គិតរួមទាំងបុគ្គលិកផ្លូវអាកាស នាវាសមុទ្រ និងអ្នកបម្រើក្នុងផ្ទះ ព្រមទាំងបុគ្គលស្វ័យនិយោជន៍។

សេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម បានរៀបចំដោយអនុលោមតាមទម្រង់ដែលបានណែនាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងត្រូវបានរៀបចំឡើងដោយក្រុមអ្នកច្បាប់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី និងបានសិក្សាស្រាវជ្រាវ ពិគ្រោះយោបល់ជាមួយក្រុមអ្នកជំនាញការផ្នែកច្បាប់ជាតិ និង ជាមួយដៃគូ-អភិវឌ្ឍនានា ជាពិសេសភាគីនិយោជក និងសហជីព។ សេចក្តីព្រាងច្បាប់ ត្រូវបានដាក់ឆ្លងការប្រជុំបច្ចេកទេសចំនួន ៨លើក ប្រជុំអន្តរក្រសួងនៅថ្ងៃ២៨-២៩ ខែមិថុនា ឆ្នាំ២០១៨។ រីឯជំពូកស្តីពីទោសប្បញ្ញត្តិត្រូវបានពិភាក្សាជាមួយក្រសួងយុត្តិធម៌។

**ឯកឧត្តម ផៃ ស៊ីផាន** បន្តថា សេចក្តីព្រាងច្បាប់នេះពិតជាមានសារៈសំខាន់បំផុត សម្រាប់បុគ្គលដែលស្ថិតនៅក្នុងវិស័យ-សាធារណៈ បុគ្គលដែលស្ថិតក្នុងវិស័យឯកជន និងបុគ្គលស្វ័យនិយោជន៍ ទទួលបាននូវរបបសន្តិសុខសង្គម ផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកនិកម្មភាពការងារចូលរួមចំណែកក្នុងការលើកកម្ពស់ជីវភាព ភាពថ្លៃថ្នូរ និងភាពសុខដុមរមនាក្នុងសង្គម។ សេចក្តីព្រាងច្បាប់នេះ ក៏ជាបទដ្ឋានគតិយុត្តដ៏សំខាន់សម្រាប់អនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤៕









# ការចូលរួមអនុវត្តផែនការសកម្មភាព សុវត្ថិភាពចរាចរណ៍ផ្លូវគោក ចំពោះកម្មករនិយោជិត ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ បេឡាជាតិរបបសន្តិសុខសង្គម និងក្រសួង ស្ថាប័ន អង្គភាព សមត្ថកិច្ចពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ ដែលជាដៃគូសហការ នឹងបង្កើននូវកិច្ចសហការក្នុងការចូលរួមផ្សព្វផ្សាយអប់រំច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក

**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាសមាជិកគណៈកម្មការសុវត្ថិភាព-ផ្លូវគោក និងជាប្រធានក្រុមការងារសុវត្ថិភាពសម្រាប់គាំពារ-កម្មករនិយោជិត (ស.ផ.ក) នៃប.ស.ស. ក្នុងកិច្ចប្រជុំត្រួតពិនិត្យ និងកែសម្រួលលើសេចក្តីព្រាងលទ្ធផលការងារសម្រេចបានប្រចាំឆមាសទី១ឆ្នាំ២០១៩ និងទិសដៅការងារអនុវត្តបន្ត របស់ក្រុមការងារ-សុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត នៃបេឡាជាតិរបបសន្តិសុខសង្គម នៅសាលប្រជុំប.ស.ស.បានថ្លែងថា៖

ថ្វីត្បិតតែករណីគ្រោះថ្នាក់ចរាចរណ៍នៅតែបន្តកើតមានឡើង ដែលជាកង្វល់របស់រាជរដ្ឋាភិបាល តាមរយៈការដាក់ចេញនូវផែនការយុទ្ធសាស្ត្រ និងទិសដៅអនុវត្តបន្តក៏ដោយ តែយើងជឿជាក់យ៉ាងមុតមាំថា នឹងអាចជួយឱ្យប្រសើរឡើង នូវសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់ការធ្វើដំណើររបស់បងប្អូនកម្មករនិ-យោជិតដែលជាផ្នែកមួយក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចសង្គម និងចូលរួមកាត់បន្ថយភាពក្រីក្រ របស់បងប្អូនកម្មករនិយោជិត ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល តាមរយៈការសហការរវាងក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) ជាមួយនឹងក្រសួង ស្ថាប័ន អង្គភាព សមត្ថកិច្ចពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ ដែលមានតួនាទីសំខាន់ក្នុងការចូលរួមលើកកម្ពស់សុវត្ថិភាពចរាចរណ៍ផ្លូវគោកដល់កម្មករនិយោជិត។



គិតចាប់ពីថ្ងៃទី១ ខែមករា រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩នេះ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានចុះផ្សព្វផ្សាយអប់រំដល់កម្មករនិយោជិតបានចំនួន ១៣២លើក នឹងមានអ្នកចូលរួមចំនួន ៧ ៨០០នាក់ នឹងផ្សព្វផ្សាយអប់រំដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិតចំនួន ១៥០លើក មានអ្នកចូលរួមសរុបចំនួន ៨ ៤៣៨នាក់។ បើទោះជាយ៉ាងនេះក្តីនៅក្នុងឆមាសទី១ ឆ្នាំ២០១៩ កន្លងទៅថ្មីៗនេះមានករណីគ្រោះថ្នាក់ចរាចរណ៍កើតឡើងចំនួន ៧៦៦លើក គ្រោះថ្នាក់ដោយសាររថយន្តចំនួន ២០លើក (ក្នុងនោះមាន ៧លើករថយន្តដឹកកម្មករនិយោជិត ក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង) ម៉ូតូចំនួន ៧០៥លើក ម៉ូតូសណ្តោងរ៉ឺម៉កចំនួន ៦លើក កង់ចំនួន ៦លើក និងថ្មើរជើងចំនួន ២៩លើក ដែលមានជនរងគ្រោះសរុបចំនួន ៩៤៤នាក់ ក្នុងនោះគ្រោះថ្នាក់រហូតដល់ស្លាប់មានចំនួន ២៤នាក់ អ្នករបួសធ្ងន់ចំនួន ១៥៩នាក់ និងអ្នករបួសស្រាលចំនួន ៧៦១នាក់ ។









ចំនួនគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកទាំង ៧៦៦លើក មានបងប្អូនកម្មករនិយោជិត ក្នុងវិស័យរោងចក្រកាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង ចំនួន ៣៥៤លើក មានជនរងគ្រោះសរុបចំនួន ៥០១នាក់ (ស្លាប់ ៧នាក់ របួសធ្ងន់ ៥៣នាក់ និងរបួសស្រាល ៤៤១នាក់) វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ ១០៨លើក មានជនរងគ្រោះសរុបចំនួន ១១៧នាក់ (ស្លាប់ ១នាក់ របួសធ្ងន់ ២០នាក់ និងរបួសស្រាល ៩៦នាក់) និងវិស័យផ្សេងៗ ៣០៤លើក មានជនរងគ្រោះសរុបចំនួន ៣២៦នាក់ (ស្លាប់ ១៦នាក់ របួសធ្ងន់ ៨៦នាក់ និងរបួសស្រាល ២២៤នាក់) ។

**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល បានថ្លែងបន្តទៀតថា៖ ក្នុងការចូលរួមអនុវត្តផែនការសកម្មភាព " សុវត្ថិភាពចរាចរណ៍ផ្លូវគោកចំពោះកម្មករនិយោជិត" ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ បេឡាជាតិរបបសន្តិសុខសង្គម និងក្រសួង ស្ថាប័ន អង្គភាព សមត្ថកិច្ចពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ ដែលជាដៃគូសហការ ត្រូវបង្កើននូវកិច្ចសហការក្នុងការចូលរួមផ្សព្វផ្សាយអប់រំច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក សុវត្ថិភាពក្នុងការធ្វើដំណើរគ្រប់រូបភាព ក្នុងន័យចូលរួមកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ដែលអាចធ្លាក់មកលើកម្មករនិយោជិតឱ្យនៅកម្រិតទាបបំផុត ។

សូមបញ្ជាក់ថា៖ កិច្ចប្រជុំខាងលើនេះ ប្រព្រឹត្តទៅនៅថ្ងៃព្រហស្បតិ៍ ២រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ ដោយមានវត្តមានចូលរួមពី ឯកឧត្តម លោក លោកស្រី ដែលជាអនុប្រធាន និងសមាជិក នៃក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) នៃ ប.ស.ស. ៕




# ប្រតិភូ នៃបេឡាជាតិរបបសន្តិសុខសង្គមកម្ពុជា ចូលរួមកិច្ចប្រជុំសមាគមសន្តិសុខសង្គមអាស៊ានលើកទី៣៦ នៅប្រទេសប្រ៊ុយណេ

**ឯកឧត្តម អ៊ឹក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដឹកនាំប្រតិភូ ចូលរួមកិច្ចប្រជុំសមាគមសន្តិសុខសង្គមអាស៊ានលើកទី៣៦ (36th ASSA Board Meeting) ក្រោមប្រធានបទស្តីពី "បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង ឥទ្ធិពលផ្នែកនវានុវត្តន៍ របបសន្តិសុខសង្គម" ដែលប្រព្រឹត្តទៅរយៈពេលពីរថ្ងៃ គឺចាប់ពីថ្ងៃទី១៧-១៨ ខែកញ្ញា ឆ្នាំ២០១៩ នៅរាជធានីបង់ដារសិរីបេហ្គាវ៉ាន់ (Bandar Seri Begawan) នៃប្រទេសប្រ៊ុយណេដារូសាលឹម (Brunei Darussalam)។

**ឯកឧត្តម** Dato Paduka Seri Haji Aminuddin Ihsan រដ្ឋមន្ត្រីនៃក្រសួងវប្បធម៌ យុវជន និងកីឡា នៃប្រទេសប្រ៊ុយណេ បានអញ្ជើញជាអធិបតីភាពបើកកិច្ចប្រជុំសមាគមសន្តិសុខសង្គមអាស៊ានលើកទី៣៦ព្រមទាំងមានការចូលរួមពីសំណាក់លោកជំទាវ Nguyen Thi Minh អនុរដ្ឋមន្ត្រី អគ្គនាយកនៃអង្គភាពសន្តិសុខសង្គមវៀតណាម និង ជាប្រធានសមាគមសន្តិសុខសង្គមអាស៊ាន លោក Dao Viet Anh អគ្គលេខាធិការ ASSA ថ្នាក់ដឹកនាំ និងតំណាងអង្គភាពសន្តិសុខសង្គម អាស៊ាន តំណាងអង្គការអន្តរជាតិខាងការងារ (ILO) តំណាងសមាគមសន្តិសុខសង្គមអន្តរជាតិ (ISSA) និងមន្ត្រីរាជការ នៃរាជរដ្ឋាភិបាលប្រ៊ុយណេ ប្រមាណ ២០០នាក់ ។






ក្នុងឱកាសនោះដែរ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏បានទទួល ពានរង្វាន់ ស្តីពីការផ្តល់សេវាធានារ៉ាប់រងសុខភាពសម្រាប់មន្ត្រីរាជការ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន (Health Care Scheme for Public Employees Former Civil Servants and Veterans) ពីលោកជំទាវ Nguyen Thi Minh ប្រធាន-សមាគមសន្តិសុខសង្គមអាស៊ានផងដែរ។

គួរបញ្ជាក់ផងដែរថា បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) នឹងទទួលតំណែងជាអនុប្រធានបន្តវេន នៃសមាគមសន្តិសុខសង្គមអាស៊ាន (ASSA) និងត្រៀមរៀបចំជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំសមាគមសន្តិសុខសង្គមអាស៊ានលើកទី ៣៧ (the 37th ASSA Board Meeting) ដែលនឹងប្រព្រឹត្តទៅនៅព្រះរាជាណាចក្រកម្ពុជា នាឆ្នាំ២០២០ ខាងមុខនេះ។








គួររំលឹកផងដែរថា៖ កន្លងមក ប.ស.ស. ធ្លាប់បានទទួលពានរង្វាន់ ចំនួន៣លើករួចមកហើយ ដែលលើកទី១ ទទួលបានពានរង្វាន់អង្គភាពឆ្នើមក្នុងការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារប្រកបដោយប្រសិទ្ធភាពខ្ពស់ (Innovation-Recognition Award: Employment Injury Insurance, EII) ពីសមាគមសន្តិសុខសង្គមអាស៊ាន (ASSA) កាលថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ នៅប្រទេសសឹង្ហបុរី នាកិច្ចប្រជុំក្រុមប្រឹក្សាភិបាល (ASSA) លើកទី៣២។ លើកទី២ ទទួលបានពានរង្វាន់ឆ្នើមស្តីពី ការគ្របដណ្តប់ផ្នែកការធានារ៉ាប់រងសន្តិសុខសង្គមប្រកបដោយប្រសិទ្ធភាពខ្ពស់ (INSURANCE COVERAGE EXCELLENCE AWARD ON HEALTH INSURANCE SCHEME) កាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៦ ពីសមាគមសន្តិសុខសង្គមអាស៊ាន (ASSA) នៅប្រទេសហ្វីលីពីន។ លើកទី៣ ទទួលបានពានរង្វាន់ ស្តីពីការផ្តល់សេវាល្អសម្រាប់របបថែទាំសុខភាព (Customer Service Health Insurance Scheme) ពីសមាគមសន្តិសុខសង្គមអាស៊ាន កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨ នៅទីក្រុង Nha Trang ប្រទេសវៀតណាម៕









# ថ្នាក់ដឹកនាំ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចូលរួមសិក្ខាសាលា ILO/អាស៊ាន ស្តីពីអនាគតកិច្ចគាំពារសង្គមក្នុងតំបន់អាស៊ាន

**ឯកឧត្តម ស៊ុំ សោភ័ណ** នាយករង ប.ស.ស. តំណាង **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញទៅចូលរួមសិក្ខាសាលា ILO/អាស៊ាន ស្តីពីអនាគតកិច្ចគាំពារសង្គមក្នុងតំបន់អាស៊ាន នៃទីក្រុងបាងកកប្រទេសថៃ។

គោលបំណងនៃសិក្ខាសាលាខាងលើនេះ ផ្តោតទៅលើចំណុចសំខាន់ៗចំនួន៤ គឺ៖

- ការលើកកម្ពស់កិច្ចសន្ទនាគោលនយោបាយស្តីពីអនាគតកិច្ចគាំពារសង្គមក្នុងតំបន់អាស៊ាន
- ការពិភាក្សាផ្នែកបច្ចេកទេស ស្តីពីអនុសាសន៍ជាក់ស្តែង និងជម្រើសគោលនយោបាយសម្រាប់ពង្រីកការគ្របដណ្តប់កិច្ចគាំពារសង្គមក្នុងតំបន់អាស៊ាន
- ការពង្រីកកិច្ចគាំពារសង្គមទៅដល់កម្មករក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធក្នុងតំបន់អាស៊ាន
- ការធានាសន្តិសុខប្រាក់ចំណូលមនុស្សចាស់ក្នុងរដ្ឋជាសមាជិកអាស៊ាន៖ ចក្ខុវិស័យ នៃគោលនយោបាយជាគន្លឹះ និន្នាការ បញ្ហាប្រឈម និងកាលានុវត្តិភាព។

សូមបញ្ជាក់ថា៖ សិក្ខាសាលាខាងលើនេះ ប្រព្រឹត្តទៅចំនួន២ថ្ងៃ គឺចាប់ពីថ្ងៃទី៤ រហូតដល់ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៩ ដោយមានការចូលរួមមកពីតំណាងរដ្ឋាភិបាល នៃរដ្ឋជាសមាជិកអាស៊ាន តំណាងនិយោជកនៃរដ្ឋជាសមាជិកអាស៊ាន តំណាងកម្មករនិយោជិតនៃរដ្ឋជាសមាជិកអាស៊ានតំណាងមកពីកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ាន (SLOM) តំណាងមកពីកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីសុខុមាលភាពសង្គម និងការអភិវឌ្ឍ (SOMSWD) តំណាងសមាជសម្ព័ន្ធសហជីពអាស៊ាន (ATUC) តំណាងសហព័ន្ធនិយោជកអាស៊ាន (ACE) តំណាងមកពីលេខាធិការដ្ឋានអាស៊ាន សមាគមសន្តិសុខសង្គមអាស៊ាន (ASSA) តំណាងក្រសួងសុខាភិបាល តំណាងអង្គការការងារ និងសុខុមាលភាព នៃប្រទេសជប៉ុន និងអង្គការអន្តរជាតិខាងការងារ (ILO) សរុបប្រមាណជាង ៥០នាក់ ៕



# កិច្ចប្រជុំពិគ្រោះយោបល់ជាមួយមូលដ្ឋានសុខាភិបាលឯកជន បញ្ហាប្រឈមក្នុងការអនុវត្តការងារក្នុងភាពជាដៃគូជាមួយ បេឡាជាតិរបបសន្តិសុខសង្គម ជូនដល់សមាជិក ប.ស.ស.

ក្រោមការចាត់តាំងរបស់ **ឯកឧត្តម អ៊ិត សំហេង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស. នៅថ្ងៃចន្ទ ៦រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៩ ដឹកនាំដោយ **ឯកឧត្តម ស៊ុំ សោភ័ណ** នាយករង ប.ស.ស. បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយមូលដ្ឋានសុខាភិបាលឯកជនបញ្ហាប្រឈមក្នុងការអនុវត្តការងារក្នុងភាពជាដៃគូជាមួយបេឡាជាតិរបបសន្តិសុខសង្គម ជូនដល់សមាជិក ប.ស.ស. ជាមួយនឹងតំណាងថ្នាក់ដឹកនាំមូលដ្ឋានសុខាភិបាលឯកជនជាដៃគូ ប.ស.ស. សរុបប្រមាណជិត ១០០នាក់ នៅសាលប្រជុំធំ នៃទីស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ។

**ឯកឧត្តម** នាយករងបានបញ្ជាក់ថា៖ កិច្ចប្រជុំនេះ ផ្តោតសំខាន់ទៅលើបញ្ហាប្រឈម អំពីការបំពេញទម្រង់បែបបទរដ្ឋបាលទាក់ទង ប.ស.ស. និងដំណើរការទូទាត់ថ្លៃសេវាជូនដល់មូលដ្ឋានសុខាភិបាលទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងឯកជនទាំងអស់ ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស. ត្រូវពង្រឹងការយកចិត្តទុកដាក់បន្ថែមទៀតទាក់ទងទៅនឹងការមកទទួលសេវាពិនិត្យ ព្យាបាលជំងឺរបស់សមាជិក ប.ស.ស. ប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។





**ឯកឧត្តម** នាយករង បានបន្ត-ទៀតថា៖ កម្មករនិយោជិតមួយចំនួន នៅមិនទាន់យល់ដឹងច្បាស់ពីនីតិវិធីក្នុងការទៅទទួលសេវាពិនិត្យ និងព្យាបាលជំងឺដោយឥតគិតថ្លៃនៅតាមមន្ទីរពេទ្យដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស. នៅឡើយទេ ដូច្នេះដើម្បីឱ្យកាន់តែមានភាពល្អប្រសើរឡើង សូមឱ្យមានការចូលរួមដោយយកចិត្តទុកដាក់បន្ថែមទៀតពីខាងមន្ទីរពេទ្យដែលជាដៃគូ ប.ស.ស.។

បច្ចុប្បន្ន បេឡាជាតិរបបសន្តិសុខ-សង្គម (ប.ស.ស.) បានចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលសាធារណៈ និងមន្ទីរពេទ្យឯកជនសរុបចំនួន ១ ៣៣៧ មូលដ្ឋានសុខាភិបាល ក្នុងនោះមានមន្ទីរពេទ្យរដ្ឋចំនួន ១ ២៩២ មូលដ្ឋានសុខាភិបាលនិងមន្ទីរពេទ្យឯកជនចំនួន ៤៥ មូលដ្ឋានសុខាភិបាល ដើម្បីសម្រួលដល់ការផ្តល់សេវាជូនសមាជិក ប.ស.ស. ឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធ-ភាព។នេះគឺជាការឆ្លើយតប ស្របតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គ-មហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលតម្រូវឱ្យកម្មករនិយោជិតទាំងក្នុង និងក្រៅប្រព័ន្ធទាំងអស់ទទួលបានសេវាគាំពារសង្គម ដើម្បីរក្សាសុខុមាលភាព និងរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់បងប្អូនកម្មករនិយោជិតឱ្យកាន់តែប្រសើរឡើង៕










# មន្ត្រីបេឡាជាតិរបបសន្តិសុខសង្គម ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា ចូលរួមកិច្ចប្រជុំស្តីពីការផ្លាស់ប្តូរចំណេះដឹងពហុប្រទេស ផ្នែកធានារ៉ាប់រងសុខភាព នៅទីក្រុងបាងកក ប្រទេសថៃ

នៅក្នុងកិច្ចប្រជុំស្តីពីការផ្លាស់ប្តូរចំណេះដឹងពហុប្រទេស ផ្នែកធានារ៉ាប់រងសុខភាព នៅទីក្រុងបាងកក ប្រទេសថៃ **ឯកឧត្តម អ៊ឹុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈ បានចាត់ប្រតិភូ ប.ស.ស. ក្នុងស្ថាប័នរបស់ខ្លួនចំនួន៣នាក់ ដឹកនាំដោយ **ឯកឧត្តម ស៊ុំ សោភ័ណ** នាយករង ប.ស.ស. ទៅចូលរួមក្នុងកិច្ចប្រជុំដ៏សំខាន់មួយនេះ ។

**ឯកឧត្តម ស៊ុំ សោភ័ណ** នាយករង ប.ស.ស. បានឱ្យដឹងថា គោលបំណងនៃកិច្ចប្រជុំនេះ ផ្តោតសំខាន់លើដំណាក់កាលផ្សេងគ្នានៃការបង្កើត និងពង្រីកការគ្របដណ្តប់ការធានារ៉ាប់រងសុខភាព រួមទាំងផ្តោតលើបញ្ហាប្រឈមដូចខាងក្រោម៖

- ការបញ្ជាទិញជាយុទ្ធសាស្ត្រ
- ការការពារ នៃការគៃបន្លំ និងអំពើពុករលួយ





- ដំណោះស្រាយផ្នែកព័ត៌មានវិទ្យា
- ការបង្កើតឱ្យមានជាស្ថាប័ននៃការធានារ៉ាប់រងសុខភាពនៅថ្នាក់កណ្តាល និងថ្នាក់ក្រោម
- ការទំនាក់ទំនង ព័ត៌មាន និងការពង្រឹងសមត្ថភាព។

កិច្ចប្រជុំស្តីពីការផ្លាស់ប្តូរចំណេះដឹងពហុប្រទេស ផ្នែកធានារ៉ាប់រងសុខភាព នៅទីក្រុងបាងកក ប្រទេសថៃខាងលើនេះ ធ្វើឡើងក្រោមការរៀបចំ និងគាំទ្រដោយកិច្ចសហប្រតិបត្តិអាល្លឺម៉ង់ ( GIZ ) ដែលប្រព្រឹត្តទៅរយៈពេល៤ថ្ងៃ ចាប់ពីថ្ងៃអង្គារ ១៤រោច ខែអាសាឍ ដល់ថ្ងៃសុក្រ ២កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែកក្កដា ដល់ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩ ដែលបេឡាជាតិរបបសន្តិសុខសង្គម ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា ដឹកនាំដោយ **ឯកឧត្តម ស៊ុំ សោភ័ណ** នាយករង ប.ស.ស. រួមដំណើរដោយ លោក ស្រិល ស៊ីថាត មន្ត្រីនៃការិយាល័យធានារ៉ាប់រងសុខភាព និងលោក Hubert Zander ទីប្រឹក្សា នៃ ប.ស.ស. ដើម្បីចូលរួមកិច្ចប្រជុំ ព្រមទាំងមានការចូលរួមពីបណ្តាស្ថាប័នធានារ៉ាប់រងសុខភាព នៃប្រទេសឥណ្ឌា នេប៉ាល់ ប៉ាគីស្ថាន និងប្រទេសថៃ សរុបប្រមាណជា៤០នាក់៕









# ឯកឧត្តម ស៊ុំ សោភ័ណ នាយករង ប.ស.ស. និងមន្រ្តីជំនាញ ចំនួន ២រូបផ្សេងទៀត ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការត្រួតពិនិត្យតាមដាន និងវាយតម្លៃលើប្រព័ន្ធគាំពារសង្គម

ក្រោមកិច្ចសហការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយនឹងអង្គការអន្តរជាតិខាងការងារ (ILO) បានរៀបចំវគ្គបណ្តុះបណ្តាលមួយ ស្តីពីការត្រួតពិនិត្យតាមដាន និងវាយតម្លៃលើប្រព័ន្ធគាំពារសង្គម ដែលប្រព្រឹត្តទៅនៅសណ្ឋាគារ Raffle Hotel Le Royal រាជធានីភ្នំពេញ។

វគ្គបណ្តុះបណ្តាលខាងលើនេះ គឺផ្តោតសំខាន់លើការបង្កើនសមត្ថភាពនៃតួអង្គសំខាន់ៗ ដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យតាមដាន និងវាយតម្លៃលើក្របខ័ណ្ឌគាំពារសង្គម ការបង្កើនសមត្ថភាពលើការបកស្រាយនូវសូចនាករកិច្ចគាំពារសង្គម ការបង្កើនសមត្ថភាពធ្វើរបាយការណ៍ស្តីពីកិច្ចគាំពារសង្គម និងការផ្តល់អនុសាសន៍ដែលផ្អែកលើតម្លៃ នៃសូចនាករសម្មតិកម្ម។

សូមបញ្ជាក់ថា៖ វគ្គបណ្តុះបណ្តាលខាងលើនេះ មានរយៈ២ថ្ងៃ គឺចាប់ពីថ្ងៃទី១៣ ដល់១៤ ខែសីហា ឆ្នាំ២០១៩ ដោយមានវត្តមានចូលរួមពី **ឯកឧត្តម ចន ណារិទ្ធ** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិគាំពារសង្គម **ឯកឧត្តម ស៊ុំ សោភ័ណ** នាយករង នៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) ព្រមទាំងមានការចូលរួមពីតំណាងក្រសួង ស្ថាប័ន អង្គការដៃគូជាតិ អន្តរជាតិ និងអង្គភាពពាក់ព័ន្ធនានា សរុបប្រមាណជាង ៣០នាក់៕





# មន្ត្រី ប.ស.ស. រៀបចំកិច្ចប្រជុំពិភាក្សាលើកម្មវិធីពិគ្រោះ និងផ្តល់យោបល់ជុំវិញកិច្ចសហការ ស្តីពីវេទិកានៃបច្ចេកវិទ្យាទំនាក់ទំនងព័ត៌មានសន្តិសុខសង្គមជាមួយភាគីពាក់ព័ន្ធ

**ឯកឧត្តម សួន ស៊ីនៀង** នាយករង ប.ស.ស. និងតំណាង **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ត្រី ព្រមទាំងបុគ្គលិក បានរៀបចំកិច្ចប្រជុំពិភាក្សាលើកម្មវិធីពិគ្រោះ និងផ្តល់យោបល់ជុំវិញកិច្ចសហការ ស្តីពី «វេទិកានៃបច្ចេកវិទ្យាទំនាក់ទំនងព័ត៌មានសន្តិសុខសង្គម (Security ICT Platform)» ដោយមានការចូលរួមពីភាគីអង្គការ JICA និងក្រុមហ៊ុន Hitachi, LTD សរុបប្រមាណ ២០នាក់។



**ឯកឧត្តម** បានលើកឡើងថា កិច្ចប្រជុំនេះមានគោលបំណង រៀបចំ និងបង្កើតទិន្នន័យ ដើម្បីគ្រប់គ្រងទៅលើទិន្នន័យរបស់កម្មករនិយោជិតទាំងក្រៅ និងក្នុងប្រព័ន្ធ និងត្រួតពិនិត្យរាល់ប្រតិបត្តិការចុះបញ្ជីកម្មករនិយោជិត តាមប្រព័ន្ធបច្ចេកវិទ្យា និងគមនាគមន៍ ដោយផ្តល់ការគាំទ្រដល់ប្រតិបត្តិការប្រព័ន្ធឯករាជ្យ និងពិភាក្សាកែសម្រួលលំហូរប្រតិបត្តិការប្រព័ន្ធថែទាំសុខភាព សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ។

សូមបញ្ជាក់ថា កិច្ចប្រជុំខាងលើនេះ ប្រព្រឹត្តទៅនៅថ្ងៃពុធ ១២ រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១៩ នៅសាលប្រជុំ នៃស្នាក់ការកណ្តាល ប.ស.ស.៕











# មន្ត្រីជំនាញបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា ចូលរួមសិក្ខាសាលាថ្នាក់តំបន់អាស៊ីអាគ្នេយ៍ និងតំបន់អាស៊ីប៉ាស៊ីហ្វិកនៅទីក្រុង New Delhi ប្រទេសឥណ្ឌា

ទាក់ទងទៅនឹងសិក្ខាសាលាថ្នាក់តំបន់អាស៊ីអាគ្នេយ៍ និងតំបន់អាស៊ីប៉ាស៊ីហ្វិកខាងលើនេះ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចាត់ **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** ប្រធានការិយាល័យគោលនយោបាយ តំណាងឱ្យបេឡាជាតិរបបសន្តិសុខសង្គមកម្ពុជា ដើម្បីចូលរួមសិក្ខាសាលាទ្វេភាគីលើកទី៤ រវាងតំបន់អាស៊ីអាគ្នេយ៍ និងតំបន់អាស៊ីប៉ាស៊ីហ្វិក ស្តីពី "គោលនយោបាយហិរញ្ញប្បទានសុខាភិបាល ក្នុងការអនុវត្តយុទ្ធសាស្ត្រចំណាយដើម្បីប្រសិទ្ធភាព និងប្រសិទ្ធផល" ក្រោមកិច្ចសហការ ឧបត្ថម្ភគាំទ្រដោយអង្គការ WHO – World Bank។

គោលបំណងនៃសិក្ខាសាលាខាងលើនេះ គឺផ្តោតទៅលើចំណុចសំខាន់ៗចំនួន៤ គឺ៖

-ចែករំលែកបទពិសោធន៍ពីបណ្តាប្រទេសមួយចំនួនក្នុងតំបន់អាស៊ីអាគ្នេយ៍ និងតំបន់អាស៊ីប៉ាស៊ីហ្វិកក្នុងនោះក៏មានប្រទេសកម្ពុជាផងដែរ

-ដើម្បីសិក្សា និងស្វែងរកដំណោះស្រាយដើម្បីជាយន្តការសម្រាប់អនុវត្តលើយុទ្ធសាស្ត្រចំណាយ ប្រកបដោយប្រសិទ្ធិភាព និងប្រសិទ្ធផល

-សិក្សាពីតម្លៃ និងវិធីសាស្ត្រនៃការចុះកិច្ចព្រមព្រៀងរវាងមូលដ្ឋានសុខាភិបាលសាធារណៈ និងមូលដ្ឋានសុខាភិបាលឯកជន ដើម្បីឱ្យមានតម្លាភាព

-សិក្សាពីយន្តការនៃការទូទាត់សេវា ដើម្បីឱ្យសមស្របទៅតាមបរិបទនៃបណ្តាប្រទេសនីមួយៗ។

សូមបញ្ជាក់ថា៖ សិក្ខាសាលាខាងលើនេះ មានសមាសភាពចូលរួមចំនួន ១៤ប្រទេស រួមមានប្រទេស Armenia Bangladesh Cambodia China India Indonesia Lao PDR Malaysia Maldives Mongolia Myanmar Nepal Thailand Viet Nam តំណាងអង្គការ WHO – World Bank ព្រមទាំងអ្នកជំនាញការមកពីបណ្តាប្រទេសជាច្រើនទៀត សរុបប្រមាណជា ៩០នាក់ ដែលប្រព្រឹត្តទៅចំនួន ៤ថ្ងៃគឺចាប់ពីថ្ងៃទី១០ ដល់ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩ ស្ថិតនៅទីក្រុង NewDelhiប្រទេសឥណ្ឌា ។



# កិច្ចប្រជុំក្រុមការងារបច្ចេកទេសនៃគម្រោង SPIN ស្តីពីជម្រើសនៃការចុះបញ្ជិកា និងបង់ភាគទានចំពោះកម្មករនិយោជិតក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងពិភាក្សាអំពីការអនុវត្តការងារបន្ត

ក្រុមការងារបច្ចេកទេស នៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) ដឹកនាំដោយ **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** ប្រធានការិយាល័យគោលនយោបាយ និងជាប្រធានក្រុមការងារបច្ចេកទេស នៅថ្ងៃពុធ ២រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ បានរៀបចំកិច្ចប្រជុំស្តីពីជម្រើសនៃការចុះបញ្ជិកា និងបង់ភាគទានចំពោះកម្មករនិយោជិតក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ (អ្នករត់ម៉ូតូកង់បី និងអ្នកបម្រើក្នុងផ្ទះ) និងពិភាក្សាអំពីការអនុវត្តការងារបន្តរបស់ក្រុមការងារបច្ចេកទេស ដែលប្រព្រឹត្តទៅនៅសាលប្រជុំស្នាក់ការកណ្តាលនៃ ប.ស.ស. រាជធានីភ្នំពេញ។









គោលបំណងនៃកិច្ចប្រជុំខាងលើនេះ គឺផ្តោតសំខាន់ទៅលើចំណុចសំខាន់ចំនួន៣ គឺ៖

- ការចុះបញ្ជិកាចំពោះកម្មករនិយោជិតក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធផ្នែកថែទាំសុខភាព
- ការបង់ភាគទានចំពោះកម្មករនិយោជិតក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធផ្នែកថែទាំសុខភាព
- រៀបរាប់ពីជម្រើសដែលមានសក្តានុពល ដើម្បីសម្រួលដល់នីតិវិធី ដើម្បីមានវិសាលភាពលើក្រុមអ្នករត់ម៉ូតូកង់បី និងអ្នកបម្រើតាមផ្ទះស្ថិតក្រោមរបបសន្តិសុខសង្គមនៃ ប.ស.ស. ។

សូមបញ្ជាក់ថា កិច្ចប្រជុំនេះ មានការចូលរួមពី លោកស្រី Camille Vautier នាយកគម្រោងកិច្ចគាំពារសុខភាពសង្គមនៃអង្គការ Gret តំណាងសមាគមកិច្ចគាំពារសុខភាពសង្គម ព្រមទាំងលោក លោកស្រី ជាមន្ត្រី ប.ស.ស. ជាច្រើននាក់ទៀត៕












# អ្នកបើកបរយានយន្តដឹកកម្មករនិយោជិតចំនួន ២៩២នាក់ ទទួលបានប័ណ្ណមូលនិធិសមធម៌សុខាភិបាល

ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) នៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) នៅថ្ងៃសុក្រ ៤រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ បានរៀបចំពិធីប្រគល់ប័ណ្ណ-មូលនិធិសមធម៌សុខាភិបាល ជូនដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិត ចំនួន២៩២នាក់ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

កម្មវិធីប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** ប្រធានការិយាល័យគោលនយោបាយ និងជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) **ឯកឧត្តម ឧត្តមសេនីយ៍ត្រី អ៊ី សុខា** ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ព្រមទាំងមានការអញ្ជើញចូលរួមពីតំណាងអង្គភាព ស្ថាប័នពាក់ព័ន្ធ សមាជិក សមាជិកា និងបងប្អូនអ្នកបើកបរយានយន្តដឹកកម្មករនិយោជិតជាច្រើននាក់។





**ឯកឧត្តម ហេង សុផាន់ណារិទ្ធ** បានមានប្រសាសន៍ថា ដោយមានការយកចិត្តទុកដាក់អំពីបញ្ហាសុខភាព នឹងចូលរួមចែករំលែកនូវទុក្ខលំបាករបស់បងប្អូនអ្នកបើកយានយន្តដឹកកម្មករនិយោជិត **ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម បានអនុញ្ញាតឱ្យក្រុម-ការងារ ប.ស.ស. រៀបចំផលិត និងប្រគល់ប័ណ្ណមូលនិធិសមធម៌សុខាភិបាល ជូនដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិត នៅពេលមានបញ្ហាសុខភាព និងជួបគ្រោះថ្នាក់ផ្សេងៗ និងទទួលបានសេវាថែទាំសុខភាព (ការព្យាបាល) ដោយឥតបង់ថ្លៃ នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ចាប់ពីមណ្ឌលសុខភាព រហូតដល់មន្ទីរពេទ្យថ្នាក់ជាតិ ដែលជាបន្ទុករបស់រាជរដ្ឋា-ភិបាលបង់ថ្លៃជំនួស។







**ឯកឧត្តម** ក៏បានពន្យល់បន្ថែមអំពីនីតិវិធីក្នុងការទៅទទួលសេវាពិគ្រោះ និងព្យាបាលជំងឺទូទៅ សេវាសម្រាលកូន សេវាវះកាត់ និងសេវាសង្គ្រោះបន្ទាន់ ជូនដល់អ្នកបើកបរយាន-យន្តដឹកកម្មករនិយោជិត ដើម្បីទទួលបានសេវាឆាប់រហ័ស និងមានប្រសិទ្ធភាព។

ជាកិច្ចបញ្ចប់ **ឯកឧត្តម អ៊ី សុខា** ក៏បានអំពាវនាវដល់អ្នកបើកបររថយន្តដឹកកម្មករទាំងអស់ ធ្វើយ៉ាងណាត្រូវ៖

- គោរពច្បាប់ចរាចរណ៍ឱ្យបានខ្ជាប់ខ្ជួន
- មិនផ្ទុកកម្មករលើសចំណុះ
- ត្រូតពិនិត្យយានយន្តមុនពេលចេញទៅដឹកកម្មករ
- ធៀករថយន្តជាប្រចាំ
- ទៅប្រឡងយកប័ណ្ណបើកបរឱ្យស្របតាមប្រភេទយានយន្ត
- ចូលរួមវគ្គបណ្តុះបណ្តាលរបស់ក្រុមការងារ ប.ស.ស ស្តីពីច្បាប់ចរាចរណ៍ផ្លូវគោក
- ជាពិសេសប្រកាន់ខ្ជាប់នូវក្រមសីលធម៌ទាំង ១០ចំណុចរបស់គណៈកម្មការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក។





# កិច្ចប្រជុំផ្សព្វផ្សាយច្បាប់ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក លើមធ្យោបាយដឹកជញ្ជូន ជូនដល់អ្នកបើកបរដឹកកម្មករនិយោជិត នៅស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង

ក្រោមការចាត់តាំងរបស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម និងជាប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) និងជាសមាជិកគណៈកម្មការសុវត្ថិភាពចរាចរណ៍ផ្លូវគោក **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** ប្រធានការិយាល័យគោលនយោបាយ និងជាសមាជិកនៃក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) នៅក្នុងកិច្ចប្រជុំផ្សព្វផ្សាយច្បាប់ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក សុវត្ថិភាពចរាចរណ៍លើមធ្យោបាយដឹកជញ្ជូន ជូនដល់អ្នកបើកបរដឹកកម្មករនិយោជិត នៅស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង បានថ្លែងថា៖

ក្នុងឆមាសទី១ ឆ្នាំ២០១៩ នេះ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) នៃបេឡាជាតិ-របបសន្តិសុខសង្គម (ប.ស.ស.) បានចុះប្រជុំផ្សព្វផ្សាយអប់រំអំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ជូនដល់កម្មករនិយោជិតបានចំនួន ១៣២លើក ដោយមានអ្នកចូលរួមសរុបចំនួន ៧៨០០នាក់ បានចុះប្រជុំផ្សព្វផ្សាយអប់រំអំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ជូនដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិតបានចំនួន ១៥០លើក ដែលមានអ្នកចូលរួមសរុបចំនួន ៨៤៣៨នាក់ ។





**ឯកឧត្តម** បានបន្តទៀតថា៖ គិតត្រឹមឆមាសទី១ ក្នុងឆ្នាំ២០១៩ នេះដដែល ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស. ផ.ក) នៃ ប.ស.ស. បានធ្វើការសហការជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក រៀបចំការប្រឡងផ្តល់បណ្ណបើកបរ ជូនដល់អ្នកបើកបររថយន្តដឹកកម្មករនិយោជិតបានចំនួន ២៣លើក ដែលមានអ្នកចូលរួមសរុបចំនួន ១ ២១៦នាក់ ប្រឡងជាប់ជាស្ថាពរសរុបចំនួន ១០៧៤នាក់។

សូមបញ្ជាក់ថា៖ កិច្ចប្រជុំផ្សព្វផ្សាយខាងលើនេះ ប្រព្រឹត្តទៅកាលពីថ្ងៃសុក្រ ១០រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ ដោយមានវត្តមាន **ឯកឧត្តម នាយឧត្តមសេនីយ៍ ហ៊ឹម យ៉ាន** អគ្គស្នងការរងនគរបាលជាតិ និងជាអនុប្រធានអចិន្ត្រៃយ៍ អនុគណៈកម្មាការទី២ ព្រមទាំងមានការចូលរួមពីលោក លោកស្រីដែលជាតំណាងអង្គភាពពាក់ព័ន្ធនានា និងអ្នកបើកបររថយន្តដឹកកម្មករនិយោជិតសរុបប្រមាណជាង ១០០នាក់ នៅរោងចក្រ JIUN YE (CAMBODIA) CO.,LTD ស្ថិតនៅស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង៕










# មន្ត្រីជំនាញ នៃបេឡាជាតិរបបសន្តិសុខសង្គមកម្ពុជា ចូលរួមសិក្ខាសាលាផ្តល់សុពលភាពលើកទី១ នៃការសិក្សាថ្នាក់តំបន់ នៅប្រទេសវៀតណាម

ក្រោមការចាត់តាំង **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **លោក ជី សួរ** ប្រធានការិយាល័យព័ត៌មានវិទ្យា នៃ ប.ស.ស. បានទៅចូលរួមសិក្ខាសាលាផ្តល់សុពលភាពលើកទី១ នៃការសិក្សាថ្នាក់តំបន់ស្តីពី "ការប្រែប្រួលរបៀបនៃទំនាក់ទំនងក្នុងការងារ ក្រោមឥទ្ធិពលនៃការប្រើប្រាស់ ICT និងភាពគ្រប់ជ្រុងជ្រោយ នៃបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងទំនាក់ទំនងក្នុងការងារ" នៅទីក្រុងហាណូយ ប្រទេសវៀតណាម។

គោលបំណងនៃសិក្ខាសាលាខាងលើនេះ គឺផ្តោតទៅលើចំណុចសំខាន់ៗចំនួន៣ រួមមាន ៖

១. ចែករំលែកព័ត៌មានពាក់ព័ន្ធ

- និន្នាការសកល នៃការផ្លាស់ប្តូរពិភពការងារ ផលប៉ះពាល់ និងការឆ្លើយតបនៅក្នុងតំបន់អាស៊ាន
- ការរកឃើញនៃការសិក្សាស្តីពីស្ថិតិពលកម្មក្រៅប្រព័ន្ធ
- ការឆ្លើយតបប្រចាំប្រទេស (ប្រទេសម៉ាឡេស៊ី)

២. ណែនាំអំពីការរកឃើញដំបូង និងអនុសាសន៍នៃការសិក្សា

៣. ប្រមូលមតិយោបល់ពីប្រទេសជាសមាជិកអាស៊ាន ផ្អែកលើការពិភាក្សា និងការធ្វើបទបង្ហាញ។

សូមបញ្ជាក់ថា៖ សិក្ខាសាលាខាងលើនេះ ប្រព្រឹត្តទៅចំនួន ២ថ្ងៃ គឺចាប់ពីថ្ងៃទី២៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ដោយមានវត្តមានចូលរួមពីតំណាងប្រទេសជាសមាជិកអាស៊ាន តំណាងលេខាធិការដ្ឋានអាស៊ាន ទីប្រឹក្សាគម្រោងរបស់បណ្តាញ JustJob ក្រុមប្រឹក្សាសហជីពអាស៊ាន (ATUC) សហព័ន្ធនិយោជកអាស៊ាន (ACE) និងតំណាងភ្នាក់ងារពាក់ព័ន្ធនានារបស់ប្រទេសវៀតណាម ជាច្រើននាក់ផងដែរ។




# មន្ត្រីជំនាញបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កម្ពុជា ចូលរួមវគ្គបណ្តុះបណ្តាលប្រតិបត្តិ ស្តីពីគោលនយោបាយសោធន ថ្នាក់តំបន់អាស៊ីប៉ាស៊ីហ្វិកនៅទីក្រុង Selangor ប្រទេសម៉ាឡេស៊ី

ទាក់ទងទៅនឹងវគ្គបណ្តុះបណ្តាលស្តីពីគោលនយោបាយសោធន ខាងលើនេះ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចាត់ **លោក ជាន ហាប់** មន្ត្រីជំនាញ នៃការិយាល័យសោធន តំណាងឱ្យបេឡាជាតិរបបសន្តិសុខសង្គមកម្ពុជា ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលប្រតិបត្តិ ស្តីពីគោលនយោបាយសោធន ក្រោមកិច្ចសហការរៀបចំដោយ មជ្ឈមណ្ឌលបណ្តុះបណ្តាលអន្តរជាតិ (ITC) នៃអង្គការអន្តរជាតិខាងការងារ (ILO) ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក គណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ចសម្រាប់អាស៊ីប៉ាស៊ីហ្វិក នៃអង្គការសហប្រជាជាតិ (UNESCAP) អង្គការ HelpAge International និងមូលនិធិបម្រុងសម្រាប់កម្មករនិយោជិត (Employees Provident Fund of Malaysia) ។



គោលបំណង នៃវគ្គបណ្តុះបណ្តាលខាងលើនេះ គឺផ្តោតទៅលើចំណុចសំខាន់ៗចំនួន៤ គឺៈ

១. ទទួលបានការយល់ដឹងផ្នែកទ្រឹស្តី នៃតួនាទីសំខាន់ៗ និងមុខងារផ្សេងៗ នៃប្រព័ន្ធរបបប្រាក់សោធន

២. សិក្សារៀនសូត្រចំពោះជម្រើសរៀបចំសម្រាប់ប្រភេទរបបប្រាក់សោធនខុសៗគ្នា (របបជាប់ភាគទាន និងរបបមិន-ជាប់ភាគទាន) និងរបៀបដែលរបបប្រាក់សោធនទាំងនេះអាចធ្វើសមាហរណកម្មបាន

៣. វិភាគយ៉ាងម៉ត់ចត់នូវករណីសិក្សា នៃកំណែទម្រង់របបប្រាក់សោធនចំពោះផលប៉ះពាល់លើការគ្របដណ្តប់ភាពគ្រប់គ្រាន់ ចីរភាព និងការឆ្លើយតបទៅនឹងយេនឌ័រ

៤. អនុវត្តនូវជំនាញវិភាគ និងចំណេះដឹងដែល ទទួលបាន ចំពោះការរៀបចំរបបប្រាក់សោធន និងកំណែទម្រង់សំណើគម្រោង សម្រាប់បរិបទប្រទេសជាក់លាក់។

សូមបញ្ជាក់ថាៈ វគ្គបណ្តុះបណ្តាលខាងលើនេះ មានសមាសភាពចូលរួមមកពីប្រទេសជាសមាជិកអាស៊ានទាំង ១០ អ្នកជំនាញការមកពីអង្គការអន្តរជាតិខាងការងារ (ILO) និងអង្គការសង្គមស៊ីវិល សរុបប្រមាណជាង ៤០នាក់ ដែលប្រព្រឹត្តទៅចំនួន៥ថ្ងៃ គឺចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៩ ៕










# មន្ត្រីជំនាញ ប.ស.ស. កម្ពុជា និងសមាជិកអាស៊ានចំនួន ៥ប្រទេសទៀត ចូលរួមវគ្គបណ្តុះបណ្តាល និងចែករំលែកពិសោធន៍ ស្តីពីការស្តារនីតិសម្បទាសម្រាប់កម្មករជាជនពិការរាងកាយ នៅប្រទេសថៃ

**លោកឆ្លូន សំណាង** អនុប្រធានការិយាល័យស្តារនីតិសម្បទា នៃបេឡាជាតិរបបសន្តិសុខសង្គមកម្ពុជា ចូលរួមវគ្គបណ្តុះបណ្តាល និងចែករំលែកពិសោធន៍ ស្តីពីការស្តារនីតិសម្បទាសម្រាប់កម្មករជាជនពិការរាងកាយ ក្រោមការចាត់តាំងពីសំណាក់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

សម្រាប់វគ្គបណ្តុះបណ្តាល និងការចែករំលែកបទពិសោធន៍ ស្តីពីការផ្តល់សេវាស្តារនីតិសម្បទារបបសន្តិសុខសង្គម នៅប្រទេសថៃនេះ គឺមានលក្ខណៈទូលំទូលាយសម្រាប់កម្មករជាជនពិការរាងកាយ (Comprehensive Rehabilitation for Workers with Physical Disabilities) ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៥ ខែសីហា រហូតដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៩ ដែលរៀបចំឡើងដោយអង្គភាពសន្តិសុខសង្គម នៃប្រទេសថៃ (Social Security Office-SSO) និងមជ្ឈមណ្ឌលស្តារនីតិសម្បទាខាងវិជ្ជាជីវៈតំបន់ ១(Industrial Rehabilitation Center Region 1-IRC) ស្ថិតនៅខេត្តប៉ាធុមថានីនៃប្រទេសថៃ។





វគ្គបណ្តុះបណ្តាលនេះដែរ មានគោលបំណងចែករំលែកបទពិសោធន៍ទាក់ទងនឹងសេវាស្តារនីតិសម្បទា ដល់បណ្តាប្រទេសស្ថិតនៅក្នុងតំបន់អាស៊ាន ដោយផ្តោតសំខាន់ទៅលើការផ្តល់សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ ( Medical -Rehabilitation) សេវាស្តារនីតិសម្បទាផ្នែកបណ្តុះបណ្តាល-វិជ្ជាជីវៈឡើងវិញ និងការងារ (Vocational Rehabilitation and Return to Work) និងស្តារនីតិសម្បទាផ្នែកចិត្តសាស្ត្រសង្គម (Psychosocial Rehabilitation) សម្រាប់ជួយដល់កម្មករជាជនពិការដែលទទួលរងគ្រោះថ្នាក់ដោយសារការងារ ឬសមាជិកដែលពិការស្ថិតនៅក្រោមបទប្បញ្ញត្តិសន្តិសុខសង្គម (Social-Security Act) ដើម្បីឱ្យពួកគេមានឱកាសអាចត្រឡប់ទៅធ្វើការនៅតាមសហគ្រាសវិញ ឬអាចប្រកបរបរផ្ទាល់ខ្លួន និងដើម្បីរស់នៅក្នុងសង្គមបានដោយឯករាជ្យ តាមរយៈដំណើរការនៃការផ្តល់សេវាស្តារនីតិសម្បទា។

សូមបញ្ជាក់ថា នេះជាលើកទី៥ហើយ ដែលសមាជិកអាស៊ានបានដំណើរការវគ្គបណ្តុះបណ្តាល និងចែករំលែកបទពិសោធន៍ ស្តីពីការផ្តល់សេវាស្តារនីតិសម្បទារបបសន្តិសុខសង្គមរបស់ខ្លួន ដោយមានការចូលរួមពី កម្ពុជា ឡាវ មីយ៉ាន់ម៉ា សឹង្ហបុរី ហ្វីលីពីន និងម៉ាឡេស៊ី ។










# ការផ្សព្វផ្សាយអប់រំអំពីច្បាប់ចរាចរណ៍ផ្លូវគោក ជូនដល់អ្នកបើកបរយានយន្តដឹកកម្មករ នៅតែជាកិច្ចការដ៏សំខាន់ សម្រាប់ក្រុមការងារ ប.ស.ស.

ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការណ៍ជាមួយស្នងការដ្ឋាននគរបាល ខេត្តកណ្តាល និងក្រុមហ៊ុន ជេត គ្រុប រៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោក ដល់អ្នកបើកបរយានយន្តដឹកកម្មករ នៅក្នុងតំបន់ 7NG ស្ថិតនៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។

ការប្រជុំផ្សព្វផ្សាយនេះប្រព្រឹត្តទៅនៅថ្ងៃសុក្រ ៧រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ ក្រោមអធិបតីភាព **ឯកឧត្តម ហេង សុផាន់ណារិទ្ធិ** ប្រធានការិយាល័យគោលនយោបាយ និងជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម លោកឧត្តមសេនីយ៍ត្រី **ខេង សុវិន** ស្នងការរង នៃស្នងការដ្ឋាននគរបាល ខេត្តកណ្តាល លោក ជឿន សុធន ជាតំណាង លោកឧកញ៉ា ស្រី ចាន់ថន អគ្គនាយកក្រុមហ៊ុន ជេត គ្រុប មន្ត្រីបេឡាជាតិរបបសន្តិសុខសង្គម សាខាខេត្ត ព្រមទាំងតំណាងអង្គភាពពាក់ព័ន្ធ និងអ្នកបើកបរយានយន្តដឹកកម្មករ ប្រមាណជា ២០០នាក់។





នាឱកាសនោះដែរ **ឯកឧត្តម ហេង សុផាន់ណារិទ្ធិ** បានលើកឡើងថាស្របទៅនឹងការរីកចម្រើនសព្វថ្ងៃនេះ ករណីគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក បានកើតឡើងគួរឱ្យព្រួយបារម្ភ និងជាក្តីកង្វល់របស់ប្រមុខរាជរដ្ឋាភិបាល។គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក គឺជាឃាតករលាក់មុខដែលធ្វើឱ្យមនុស្សស្លាប់ របួស ពិការ និងបានបន្សល់ទុកនូវសោកនាដកម្មដ៏រន្ធត់ ដែលជាផលប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចសង្គមជាតិទាំងមូល។ បញ្ហាប្រឈមដ៏ធ្ងន់ធ្ងរនេះមិនអាចឱ្យ ក្រសួង ស្ថាប័ន ឬផ្នែកណាមួយធ្វើការទប់ស្កាត់ កាត់បន្ថយ ឬលុបបំបាត់តែឯងបានឡើយ។ ប៉ុន្តែយើងអាចសហការគ្នាទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ឱ្យស្ថិតមកនៅក្នុងកម្រិតទាប។ ស្របពេលជាមួយគ្នានោះដែរ រាជរដ្ឋាភិបាលកម្ពុជាបានលើកទឹកចិត្ត និងជំរុញឱ្យគ្រប់ផ្នែក គ្រប់វិស័យ យកចិត្តទុកដាក់ខ្ពស់បំផុតចំពោះបញ្ហាសុវត្ថិភាពចរាចណ៍ផ្លូវគោក។








ដូច្នេះហើយទើប ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្កើតក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) នៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមលើកកម្ពស់សុវត្ថិភាពចរាចរណ៍ផ្លូវគោករបស់កម្មករនិយោជិត ដើម្បីចូលរួមបង្ការ និងទប់ស្កាត់ ករណីគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោករបស់កម្មករនិយោជិត។









ជាមួយគ្នានេះ លោកឧត្តមសេនីយ៍ត្រី **ទេព សុទិន ស្នងការរង** នៃស្នងការដ្ឋាននគរបាល ខេត្តកណ្តាល បានពន្យល់អំពីបញ្ហាគ្រោះថ្នាក់ចរាចរណ៍ដែលតែងតែកើតមានឡើងជារៀងរាល់ថ្ងៃបណ្តាលមកពី៖ កត្តាមនុស្ស កត្តាយានយន្ត និងកត្តាផ្សេងៗ។ លោកឧត្តមសេនីយ៍ត្រី ក៏បានសំណូមពរទៅដល់អ្នកបើកបរយានយន្តដឹកកម្មករទាំងអស់ត្រូវតែចាំថាខ្លួន គឺជាបុគ្គលដ៏សំខាន់ក្នុងការធានានូវសុវត្ថិភាពក្នុងពេលធ្វើដំណើររបស់កម្មករនិយោជិតតាមរថយន្ត ដែលត្រូវមានទំនួលខុសត្រូវខ្ពស់ក្នុងការបើកបរដោយគោរពច្បាប់ចរាចរណ៍ ឱ្យបានខ្ជាប់ខ្ជួន ជាពិសេសប្រកាន់ខ្ជាប់នូវក្រមសីលធម៌ទាំង ១០ចំណុចរបស់គណៈកម្មការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ដើម្បីនាំមកនូវសុវត្ថិភាព និងសេចក្តីសុខគ្រប់ពេលវេលា។

ការផ្សព្វផ្សាយខាងលើនេះ មានសារៈសំខាន់ណាស់សម្រាប់អ្នកបើកបរយានយន្តដឹកកម្មករ ត្រូវតែយល់ដឹងទាំងអស់គ្នា ហើយនាំគ្នាគោរពច្បាប់ចរាចរណ៍ផ្លូវគោកឱ្យបានត្រឹមត្រូវ ដើម្បីរួមចំណែកកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ឆ្លើយតបទៅនឹងអនុសាសន៍ដ៏ខ្ពង់ខ្ពស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី (ថ្ងៃនេះ ថ្ងៃស្អែកកុំឱ្យមានគ្រោះថ្នាក់ចរាចរណ៍ ) ៕





# មើលមនុស្សដោយស្មារតី

ការសម្លឹងមើលមនុស្សដទៃក្នុងផ្នែកល្អ ជាសេចក្តីល្អម្យ៉ាង ជាការឱ្យកិត្តិយសដល់គេ និងជាការហ្វឹកហាត់ទូន្មានខ្លួន ឱ្យជាមនុស្សចិត្តទូលាយ មិនឃើញតែពីខ្លួនឯង។ ជាធម្មតាមនុស្សដោយច្រើន តែងតែសម្លឹងមើលខ្លួនឯងក្នុងផ្នែកល្អ ហើយមើលអ្នកដទៃក្នុងផ្នែកអាក្រក់។ បើយើងរៀនសម្លឹងមើលក្នុងផ្នែកផ្ទុយគ្នាពីមនុស្សដោយច្រើននោះវិញ ជាការប្រសើរណាស់ នោះគឺព្យាយាមចាប់កំហុសរបស់ខ្លួនឯង ហើយសម្លឹងមើលអ្នកដទៃក្នុងផ្នែកល្អ ដែលល្មមនឹងឱ្យឃើញបាន ទាំងនេះដើម្បីកាត់បន្ថយនូវកំហុសរបស់ខ្លួនផង និងដើម្បីសេចក្តីសប្បាយចិត្តក្នុងជីវិតរស់នៅផង។

ស្គាល់ទុក្ខដោយបញ្ញា ទើបបានសុខមិនមានជីវិតណាដែលប្រព្រឹត្តទៅដោយរាបស្មើ ប្រាសចាកទុក្ខគ្រប់យ៉ាងនោះឡើយ តែទុក្ខនោះឯង បើចេះមើល ចេះប្រើវាឱ្យល្អ នឹងជាដើមហេតុឱ្យកើតសេចក្តីសុខដ៏មាំមួន។

យើងដឹងពីភាពត្រជាក់នៃម្លប់ដើមឈើ ក៏ព្រោះមានកម្តៅថ្ងៃនៅជុំវិញ។ ជីវិតនេះកាលដែលត្រូវព័ន្ធជុំវិញទៅដោយកម្តៅថ្ងៃគឺសេចក្តីទុក្ខ អ្នកប្រាជ្ញអាចរកសេចក្តីសុខបាន ក្នុងទីដែលមានទុក្ខនៅព័ន្ធជុំវិញនោះឯង។



# អាហារ ៦ មុខសម្រាប់អ្នកភ្នែកម៉្វបមិនគួរមើលរំលង

ភ្នែក ម៉្វបត្រូវបានគេស្គាល់ថាជាការមើលឃើញខ្លី ឬមើលឃើញជិត ដែលបណ្តាលឱ្យមនុស្សមានការលំបាកក្នុងការមើលវត្ថុឆ្ងាយ។ ការកើនឡើងនូវកម្រិតម៉្វបខ្ពស់ អាចបង្កឱ្យមានគ្រោះថ្នាក់ខ្លាំងទៅលើភ្នែក រហូតអាចឈានទៅដល់ភាពពិការភ្នែក។ ដូច្នេះ ប្រភេទអាហារ៦មុខខាងក្រោមអាចជាផ្នែកមួយចូលរួមក្នុងការកាត់បន្ថយកម្រិតម៉្វប ឬរក្សាកម្រិតម៉្វបកុំឱ្យវិវឌ្ឍទៅមុខ៖

## ១. សាច់ត្រី

ត្រីជាប្រភេទអាហារដ៏ល្អសម្រាប់អ្នក ភ្នែកម៉្វប ដែលវាសម្បូរដោយអូមេហ្គា៣ ជួយឱ្យភ្នែកលោកអ្នក ភ្លឺច្បាស់ និងការពាររោគសញ្ញាភ្នែកស្ងួតបង្កពីមូលហេតុផ្សេងៗ។ ការបរិភោគសាច់ត្រីជាទៀងទាត់រៀងរាល់ថ្ងៃអាចជួយកាត់បន្ថយការវិវឌ្ឍទៅជាជំងឺភ្នែកឡើងបាយ និងការចុះខ្សោយនៃជំងឺភ្នែកនៅពេលក្រោយបានយ៉ាងប្រសើរ។

## ២. សាច់សត្វ

ការបរិភោគសាច់ជ្រូក សាច់គោ និង អយស្ទ័រសម្បូរជាតិស័ង្កសី ដែលជាសារធាតុរ៉ែផ្តល់នូវវីតាមីនA ដល់ភ្នែករបស់អ្នក។ វាក៏ជាផ្នែកមួយ ដ៏សំខាន់ក្នុងការធានានូវការផលិតជាតិមេឡានីនដែលសារជាតិពណ៌នេះទទួលខុសត្រូវចម្បងក្នុងការថែរក្សាការថតកាំរស្មីភ្នែក ជាពិសេសការពារភ្នែកងងឹតនៅពេលយប់។ ដើម្បីឱ្យកាន់តែមានប្រសិទ្ធភាព អ្នកគួរទទួលទានសាច់ក្នុងមួយថ្ងៃ យ៉ាងតិច ៣៧៥មីលីក្រាម។

## ៣. បន្លែបៃតង

បន្លែបៃតងសម្បូរទៅដោយសារជាតិ Lutein និង Zeaxanthin ដែលអាចការពារភ្នែករបស់លោកអ្នកពីកាំរស្មីពន្លឺព្រះអាទិត្យ ពិសេសការពារស្រទាប់ខាងក្នុងនៃគ្រាប់ភ្នែក។ មិនតែប៉ុណ្ណោះបន្លែបៃតងក៏ជួយបង្ការកុំឱ្យភ្នែកខ្សោយ និងកាត់បន្ថយការកើនឡើងនៃកម្រិតភ្នែកម៉្វប ប្រសិនបើអ្នកបរិភោគបន្លែប្រមាណ ១២ មីលីក្រាមរៀងរាល់ថ្ងៃ។ បន្លែទាំងនោះអាចរួមមាន ប៉េងប៉ោះដំឡូង ស្ពៃ សាឡាត់ ខាត់ណា ជាដើម។



### ៤. ផ្លែឈើ

លោកអ្នកអាចបរិភោគប្រភេទផ្លែឈើដូចជា ស្ត្របឺរី ស្វាយ ល្ហុង និងក្រូច ធ្វើជាអាហារសម្រន់បាន ព្រោះវាសម្បូរទៅដោយវីតាមីនC ជួយបង្កើនប្រព័ន្ធភាពស៊ាំក្នុងរាងកាយ បង្កើនភាពធន់នៃភ្នែកទៅនឹងជំងឺផ្សេងៗទៀត។ យ៉ាងហោចណាស់ អ្នកអាចបរិភោគផ្លែឈើចំនួន ៩០ មីលីក្រាមក្នុងមួយថ្ងៃសម្រាប់បុរស និង៧៥មីលីក្រាមក្នុងមួយថ្ងៃសម្រាប់ស្ត្រី ដើម្បីជំនួយដល់សុខភាពភ្នែករបស់អ្នក។

### ៥. គ្រាប់ធញ្ញជាតិ

ការបរិភោគគ្រាប់ធញ្ញជាតិជាប្រចាំ អាចជាដំណោះស្រាយមួយក្នុងចំណោមដំណោះស្រាយជាច្រើនដើម្បីគ្រប់គ្រងភ្នែកម៉្វប ព្រោះវាសម្បូរ ដោយវីតាមីនE ដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារប្រតិកម្មផ្សេងៗ និងថែរក្សាភ្នែកឱ្យមើលឃើញកាន់តែច្បាស់។ លោកអ្នកគ្រាន់តែទទួលទានគ្រាប់ធញ្ញជាតិដូចជា សណ្តែកដីសណ្តែកបៃតង និង ពពួកគ្រាប់ធញ្ញជាតិមួយចំនួនទៀតក្នុងបរិមាណត្រឹមតែ ០.៥ មីលីក្រាម ក្នុងមួយថ្ងៃ នោះអ្នកនឹងឃើញលទ្ធផល។

### ៦. ស៊ុត និង ការ៉ុត

ស៊ុតមានផ្ទុកទៅដោយវីតាមីនA ដែលជួយការពារភ្នែកងងឹតនៅពេលយប់ និង ភ្នែកស្ងួត។ ជាមធ្យម លោកអ្នកអាចទទួលទានស៊ុតក្នុងចន្លោះពី ១ទៅ៤គ្រាប់ ក្នុងមួយថ្ងៃ។ រីឯការ៉ុតក៏មិន ខុសគ្នាដែរ វាជាបន្លែមាននូវវីតាមីនច្រើនប្រភេទសម្រាប់លើកកម្ពស់ក្នុងការជួយឱ្យភ្នែកមានសុខភាពល្អ និងឱ្យភ្នែកមើលឃើញច្បាស់ជាងមុន។ ល្អបំផុត គួរទទួលទានទឹកការ៉ុត ប្រមាណ១១៨.២មីលីលីត្រ ឬ ការ៉ុត២០មីលីក្រាម (១ ទៅ ៤ ការ៉ុត) រៀងរាល់ថ្ងៃសម្រាប់អ្នកមានភ្នែកម៉្វប។

**ប្រភព៖https://healthtime.tips/c/1466**



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងព័ត៌មាន**
**MINISTRY OF INFORMATION**
លេខ :....៥០៤.........ព.មប្រក

ថ្ងៃ..ចន្ទ ៩កើត... ខែ..អស្សុជ..... ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី..០៧.....ខែ..តុលា.....ឆ្នាំ២០១៩

# ប្រកាស
## រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦/០៩/១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨/០៦/១៨ ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៨៩៥/០៧ ចុះថ្ងៃទី០១ /០៩/៩៥ ប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសារព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/១៤ ចុះថ្ងៃទី២៤ /០១/៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០/អនក្រ.បក ចុះថ្ងៃទី០៥/០៨/៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧១/អនក្រ.បក ចុះថ្ងៃទី១៣/០៧/០៧ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាលនិងសោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និង អគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍ របស់ក្រសួងព័ត៌មាន
- យោងប្រកាសរបស់ក្រសួងព័ត៌មានលេខ ៦២៥/០៩ ព.ម ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩ ស្តីពីការអនុញ្ញាតឲ្យបោះពុម្ពផ្សាយព្រឹត្តិបត្រ "បេឡាជាតិរបបសន្តិសុខសង្គម" ដោយមានលោក ជាវ ប៊ុនរិទ្ធ ជាចាងហ្វាងការផ្សាយ ។
- យោងលិខិតស្នើសុំផ្ទេរសិទ្ធិអាជីវកម្មព្រឹត្តិបត្រឈ្មោះ "បេឡាជាតិរបបសន្តិសុខសង្គម" ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ របស់លោក ជាវ ប៊ុនរិទ្ធ។

## សម្រេច

**ប្រការ១** : អនុញ្ញាតឲ្យផ្ទេរសិទ្ធិអាជីវកម្មព្រឹត្តិបត្រឈ្មោះ "បេឡាជាតិរបបសន្តិសុខសង្គម" ពីលោក ជាវ ប៊ុនរិទ្ធ មកលោក ហេង សុផាន់ណារិទ្ធ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០១០៨៦៨២៨២ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៤ មានអាសយដ្ឋាននៅផ្ទះ៧៣AE0E1 ផ្លូវ៤៣២ ភូមិ៣ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ ជំនួសវិញ ៖

-មានអាសយដ្ឋានទីស្នាក់ការស្ថិតនៅអាគារលេខ២០៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**ប្រការ២** : រាល់ដំណើរការបោះពុម្ពផ្សាយត្រូវគោរពតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពី របបសារព័ត៌មាន ក្រមសីលធម៌ វិជ្ជាជីវៈអ្នកសារព័ត៌មាន ត្រូវដាក់អាសយដ្ឋានទីចាត់ការព្រឹត្តិបត្រ ឈ្មោះចាងហ្វាងការផ្សាយ និងឈ្មោះអាសយដ្ឋានរោងពុម្ពនៅលើទំព័រព្រឹត្តិបត្ររបស់ខ្លួន ព្រមទាំងយកព្រឹត្តិបត្រ មួយចំនួនមកតម្កល់ទុកនៅនាយកដ្ឋានមណ្ឌលព័ត៌មាន នៃក្រសួងព័ត៌មាន និងចំនួន០២ច្បាប់ តម្កល់ទុកនៅបណ្ណាល័យជាតិ។

**ប្រការ៣** : ករណីប្រព្រឹត្តល្មើសដូចចែងក្នុងប្រការ១ និងប្រការ២ ខាងលើ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន។

**ប្រការ៤** : ប្រកាសនេះមានសុពលភាពរយៈពេល ០១(មួយ)ឆ្នាំ គិតពីថ្ងៃចុះហត្ថលេខាតទៅ។

**ប្រការ៥** : អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ ខុទ្ទកាល័យ នៃក្រសួងព័ត៌មាន មន្ទីរព័ត៌មានរាជធានីភ្នំពេញ និងអាជ្ញាធរដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**រដ្ឋមន្ត្រី**

**ខៀវ កាញារីទ្ធ**

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ (អគ្គស្នងការដ្ឋាននគរបាលជាតិ)
- ក្រសួងយុត្តិធម៌
- សាលារាជធានីភ្នំពេញ
- គ្រប់សមាគមអ្នកសារព័ត៌មាន
  "ដើម្បីជូនជ្រាប"
- ឯកសារ - កាលប្បវត្តិ

# បេឡាជាតិរបបសន្តិសុខសង្គម

## National Social Security Fund


០២៣ ៨៨ ២៤ ៣៤
០២៣ ៩៩ ៨៤ ១៧
០២៣ ៩៩ ៨៤ ១៨
០២៣ ៩៩ ៨៨ ១៩
០២៣ ៨៨ ២៦ ២៣

បេឡាជាតិរបបសន្តិសុខសង្គម
NSSF Official
www.nssf.gov.kh
info@nssf.gov.kh

អាគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
(បរិវេណក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)


